កំណត់សម្គាល់ខ្លីៗ

# របបនៃការប្រកាសទោសទូទៅ

រៀបរៀងដោយ

លោក ឡេង រតនា
និស្សិតឆ្នាំទី៤
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច



នីតិកោសល



# គោលការណ៍ឯកត្តកម្មនៃទោស

គឺតុលាការអាចធ្វើការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសនៃបទល្មើស នៅក្នុងការកំណត់នៅកម្រិតទណ្ឌកម្ម ដើម្បីដាក់អោយត្រូវទៅលើជនដែលបានប្រព្រឹត្តបទល្មើសម្នាក់ៗ។

## ការប្រកាសមូលទោស

ដោយយោងតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា របបនៃការប្រកាសមូលទោស ប្រសិនបើបទល្មើសមួយមានចែងផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង ចៅក្រម ឬតុលាការមានសិទ្ធិអំណាចក្នុងការជ្រើសរើសក្នុងការប្រកាស៖

- ទោសជាប់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា
- ទោសដាក់ពន្ធនាគារតែមួយមុខ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ

ជាងនេះទៅទៀត ចៅក្រមក៏ត្រូវកំណត់ដោយខ្លួនឯង ចំពោះថេរវេលានៃទោសជាប់ពន្ធនាគារ និងទោសពិន័យតាមឆន្ទានុសិទ្ធិរបស់ខ្លួន។



# ការប្រកាសទោសជំនួស

តាមរយៈមាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌ ការប្រកាសទោសជំនួស គឺទោសការងារសហគមន៍ ឬការស្ដីបន្ទោស ដែលត្រូវបានគេយកមកប្រកាសជំនួសឲ្យមូលទោស។ ជាក់ស្ដែង ប្រសិនបើតុលាការធ្វើការប្រកាសទោសនោះ ជាទោសការងារសហគមន៍ ឬទោសស្ដីបន្ទោស ដូច្នេះតុលាការពុំអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់។ ជាងនេះទៅទៀត តុលាការក៏ពុំអាចប្រកាសទោសជំនួសទាំងពីរនេះឲ្យត្រួតគ្នា គឺមានន័យថាទោសការងារសហគមន៍ និងទោសការស្ដីបន្ទោស ពុំអាចត្រូវបានប្រកាសព្រមពេលជាមួយគ្នា ហើយចៅក្រមក៏ពុំអាចប្រកាសទោសជំនួសនេះ ត្រួតគ្នាជាមួយនឹងទោសពន្ធនាគារ ឬទោសពិន័យបានឡើយ។



ដោយឡែក ការប្រកាសទោសការស្តីបន្ទោស (មាត្រា៧៦) តុលាការអាចធ្វើការប្រកាសបាន កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬ ស្មើនឹង ៣ឆ្នាំ ហើយត្រូវបានបំពេញគ្រប់នូវលក្ខខណ្ឌ ទាំងបីខាងក្រោមនេះ ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់។
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលមករស់នៅក្នុងសង្គមវិញ។

## ការប្រកាសទោសជំនួស

យោងតាម មាត្រា ៩៩ កាលណាបទល្មើសមួយត្រូវបានផ្តន្ទាទោសបន្ថែមមួយ ឬច្រើន ទោសនេះត្រូវបន្ថែមលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះចេញ។ បន្ថែមពីលើមូលទោស ចៅក្រមអាចសម្រេចប្រកាសទោសបន្ថែម ដោយឧទាហរណ៍៖ ការហាមឃាត់ការស្នាក់នៅ ការហាមឃាត់ការអនុវត្តវិជ្ជាជីវៈ ការព្យួរលិខិតបើកបរ។ល។



យោងតាម មាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌ កាលណាបទល្មើសមួយត្រូវបានផ្តន្ទាទោសបន្ថែមមួយ ឬច្រើន ទោសនេះត្រូវបន្ថែមលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះចេញ។ បន្ថែមពីលើមូលទោស ចៅក្រមអាចសម្រេចប្រកាស ទោសបន្ថែម ដោយឧទាហរណ៍៖ ការហាមឃាត់ការស្នាក់នៅ ការហាមឃាត់ការអនុវត្តវិជ្ជាជីវៈ ការព្យួរលិខិតបើកបរ។ល។ តុលាការអាចសម្រេចដោយសេរី ក្នុងការជ្រើសយកទោសបន្ថែមច្រើនមកអនុវត្តកាលណាច្បាប់ចែងថា ទោសបន្ថែមទាំងនេះអាចប្រកាសចំពោះបទល្មើសដែលត្រូវបានផ្តន្ទាទោសនោះ។



ចៅក្រម ក៏អាចសម្រេចជំនួសមូលទោស ដោយទោសបន្ថែមមួយ ឬច្រើន នៅក្នុងករណីដូចខាងក្រោម៖

-នៅពេលដែលជនជាប់ចោទទទួលរងនូវទោសពិន័យ ជាមូលទោសតែមួយគត់

-នៅពេលដែលជនជាប់ចោទទទួលរងនូវទោសពន្ធនាគារ ដែលមានអតិបរមាស្មើ ឬតិចជាង ៣ឆ្នាំ។

ក្នុងករណីដែល ចៅក្រមសម្រេចជំនួសមូលទោស ដោយទោសបន្ថែមមួយ ឬច្រើន ដូច្នេះតុលាការពុំអាចធ្វើការប្រកាស ទោសពន្ធនាគារ ឬទោសពិន័យឡើយ។

សរុបសេចក្តីមក របបនៃការប្រកាសទោស គឺបានផ្តល់នូវអំណាចរបស់ចៅក្រម នៅក្នុងការប្រកាសទោស ឲ្យមានលក្ខណៈសមស្របទៅនឹងព្យសនៈកម្មដែលបានកើតមានឡើងដោយជនល្មើសលើជនរងគ្រោះ។ ចំពោះអំណាចរបស់ចៅក្រម ក្នុងការប្រកាសទោសនេះ ក៏ត្រូវស្របទៅតាមគោលការណ៍ឯកត្តកម្មនៃទោស នៅក្នុងការប្រកាសទោសផងដែរ៕

© នីតិកោសល | ទំព័របញ្ចប់